ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១៦៧ | គ.ជ.ប
/០៧

# សេចក្ដីរំលឹក

ស្ដីពី

**ការចេញលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុនៃអ្នកសុំចុះឈ្មោះបោះឆ្នោត និងការបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ *(ទម្រង់បែបបទលេខ ១០១៨)* សម្រាប់យកទៅប្រើក្នុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧**

យោង: សេចក្ដីរំលឹក លេខ:៥៨១/០៦ គ.ជ.ប ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៦

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមរំលឹកគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ( *គខ/គក*) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ( *គឃ/គស*)ថា ដើម្បីពង្រឹងកិច្ចសហការជាមួយ អាជ្ញាធរ ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បង្កើនទូវប្រសិទ្ធភាពក្នុងការចេញលិខិតធានាអះអាងអំពីអត្តសញ្ញាណ ឬ/និងអាយុនៃអ្នកសុំចុះឈ្មោះបោះឆ្នោត និងការបញ្ជាក់ទីលំនៅក្នុង ឃុំ សង្កាត់ *(ទម្រង់បែបបទលេខ ១០១៨)* សម្រាប់យកទៅប្រើក្នុងពេលបោះឆ្នោត ដូចខាងក្រោម :

១. ចំពោះប្រជាពលរដ្ឋ ដែលមានទម្រង់បែបបទលេខ ១០១៨ ក្នុងពេលចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមិនទាន់មានបិទរូបថត សូមយករូបថត ( ៤ x ៦ ) ចំនួនពីរ ( ២ ) សន្លឹក និងទម្រង់បែបបទលេខ ១០១៨ ដែលមានស្រាប់ ទៅសុំមេឃុំ ចៅសង្កាត់បោះត្រាបញ្ជាក់ទៅលើរូបថត ដើម្បីផ្ដល់សុពលភាពសម្រាប់យកទៅប្រើក្នុងពេលបោះឆ្នោត ។

២. មេឃុំ ចៅសង្កាត់ត្រូវផ្អែកលើបញ្ជីបោះឆ្នោតឆ្នាំ ២០០៥ ដែលធ្វើបច្ចុប្បន្នភាពរួចហើយ និង បញ្ជីឈ្មោះអ្នកបោះឆ្នោតបន្ថែមសរសេរដោយដៃ ដែលមានស្រាប់នៅឃុំ សង្កាត់ ឬ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតលើកទី២ ដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ជូនប្រជាពលរដ្ឋ។

៣. ការចេញទម្រង់បែបបទលេខ ១០១៨ សម្រាប់ប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ ឆ្នាំ២០០៧ ត្រូវបញ្ឈប់នៅថ្ងៃសៅរ៍ ទី៣១ ខែមីនា ឆ្នាំ២០០៧ វេលាម៉ោង ៥ : ៣០នាទី ល្ងាច។

ទទួលបានសេចក្ដីរំលឹកលើកទី២នេះ គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវសហការគ្នាឱ្យបានល្អប្រសើរក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៧

ត.ប.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អគ្គលេខាធិការ

ទេព_នីថា